# គម្រោងអាជីវកម្ម
# ចិញ្ចឹមជ្រូកព្រៃ





រៀបចំដោយ

**នាយកដ្ឋានគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល នៃ**

**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ធ.អ.ជ.ក.)**

ខែកក្កដា ឆ្នាំ២០២៥

# មាតិកា

**១-សេចក្តីផ្តើម** ............................................................ ១

**២-លក្ខណៈទូទៅ** ............................................................ ១

**៣-បច្ចេកទេសចិញ្ចឹម** ............................................................ ១

៣-១-ការជ្រើសរើសមេបាពូជ ............................................................ ១

៣-២-វិធីសាស្រ្តចិញ្ចឹម ............................................................ ២

៣-៣-ការរៀបចំទ្រុង ............................................................ ២

៣-៤-ការផ្តល់ទឹក និងចំណី ............................................................ ៣

៣-៥-ការថែទាំសុខភាពមេជ្រូក ............................................................ ៣

៣-៦-ការថែទាំសុខភាពកូនជ្រូក ............................................................ ៣

៣-៧-ការធ្វើប្រព័ន្ធជីវសុវត្ថិភាព ............................................................ ៤

៣-៨-តម្លៃ និងទីផ្សារ ............................................................ ៤

**៤-គម្រោងអាជីវកម្មចិញ្ចឹមជ្រូកព្រៃសាច់** ............................................................ ៤

៤-១-គម្រោងចិញ្ចឹម ............................................................ ៤

៤-២-ការវិភាគសេដ្ឋកិច្ច ............................................................ ៥

៤-៣-ការវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់ ............................................................ ៦

**៥-ហានិភ័យ វិធានការ និងអនុសាសន៍** ............................................................ ៧

**៦-សេចក្តីសន្និដ្ឋាន** ............................................................ ៨

## ១-សេចក្តីផ្តើម

ការចិញ្ចឹមជ្រូកព្រៃផ្តល់ផលប្រយោជន៍ច្រើនដល់ប្រជាកសិករ ខណៈដែលជ្រូកប្រភេទនេះកំពុងមានទីផ្សារល្អ ងាយស្រួលលក់ទាំងកូន ទាំងជ្រូកសាច់ និងមានតម្លៃថ្លៃជាងជ្រូកស្រុក។ ជ្រូកព្រៃងាយស្រួលចិញ្ចឹម មានភាពធន់នឹងជំងឺ ពិសេសវាស៊ីចំណីមិនរើស ស៊ីតាមបែបធម្មជាតិ ស្លឹកឈើ ស្មៅ មើមដំឡូង កន្ទក់ បាយ។ ជ្រូកព្រៃមានសាច់រឹងមិនសូវសម្បូរខ្លាញ់ មានរសជាតិឆ្ងាញ់ ទោះបីតម្លៃមានការប្រែប្រួលឡើងចុះក្នុងទីផ្សារក្តី ក៏ការចិញ្ចឹមជ្រូកព្រៃសម្រាប់បម្រើផលិតកម្មសាច់នៅតែមានស្ថេរភាពល្អ។

សម្រាប់កសិករដែលមានដីធំទូលាយ ទីធ្លាធម្មជាតិល្អ ឬជិតតំបន់ដែលសម្បូរព្រៃឈើ អាចទាញយកនូវធនធានដូចជាចំណីធម្មជាតិ ស្មៅ អនុផលព្រៃឈើ និងចំណីចម្រុះផ្សេងៗដើម្បីចិញ្ចឹមជ្រូកព្រៃសម្រាប់រកចំណូលទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ។ ដើម្បីឱ្យការចិញ្ចឹមជ្រូកព្រៃទទួលបានជោគជ័យ មានអត្រារស់ខ្ពស់ និងផលិតភាពល្អ កសិករគួរអនុវត្តន៍តាមបច្ចេកទេសសមស្របទៅនឹងស្ថានភាពបច្ចុប្បន្នដូចជា÷

- រៀបចំទ្រុងឱ្យសមស្របទៅនឹងអាកាសធាតុ
- ជ្រើសរើសពូជជ្រូកព្រៃល្អ ធន់ជំងឺ មិនសូវកាច ធំធាត់លឿន
- បង្កាត់ពូជឱ្យបានត្រឹមត្រូវ ជៀសវាងការជាន់ឈាម
- ថែទាំអនាម័យ និងសុខភាពជ្រូក
- ផ្តល់ចំណីបន្ថែមពីលើចំណីរកបានក្នុងធម្មជាតិ

## ២-លក្ខណៈទូទៅ

ជ្រូកព្រៃមានសម្បុរខ្មៅ ឬត្នោតចាស់ រោមខ្នងវែងក្រាស់ សាច់មានរសជាតិឆ្ងាញ់ ជាតិខ្លាញ់តិច។ ជ្រូកព្រៃមានការលូតលាស់យឺត មានអាកប្បកិរិយាខ្លាំងជាងជ្រូកស្រុក ត្រូវការទីតាំងដើរលេងឱ្យបានធំទូលាយ។ សម្រាប់ជ្រូកព្រៃពូជសុទ្ធ មេជ្រូកព្រៃអាចផ្តល់កូនបានពី២ដង/ឆ្នាំ ម្តងពី៦ទៅ ១០ក្បាល។

## ៣-បច្ចេកទេសចិញ្ចឹម

### ៣-១- ការជ្រើសរើសមេបាពូជ

ក-<u>មេជ្រូកពូជសម្រាប់ចិញ្ចឹមយកកូនត្រូវមាន</u>÷

-សុខភាពល្អ មិនធ្លាប់មានជំងឺ

-អាយុចាប់ពី៩ខែឡើងទៅ និងមិនលើសពី៥ឆ្នាំ

-ក្បាលដោះល្អ មិនខ្វាក់ ចន្លោះដោះពីមួយគូទៅមួយគូ ស្មើៗគ្នា

-ពូកែចិញ្ចឹមមើលថែកូន សម្បូរទឹកដោះ។

ខ-បាជ្រូកពូជសម្រាប់បង្កាត់មេ÷

-មានសុខភាពល្អ រាងកាយមាំមួន

-អាយុចាប់ពី១២ខែឡើងទៅ និងមិនលើសពី៦ឆ្នាំ

-ពូកែពាក់មេ ស្លូត មិនបង្កគ្រោះថ្នាក់ដល់ម្ចាស់ និងមនុស្សជុំវិញខ្លួន

-ស៊ីមិនរើសចំណី មិនជាន់ឈាម និងមានកែវភ្នែកភ្លឺថ្លា

## ៣-២-វិធីសាស្ត្រចិញ្ចឹម

វិធីសាស្ត្រនៃការចិញ្ចឹមជ្រូកព្រៃគឺអាស្រ័យទៅលើស្ថានភាពទីតាំងភូមិសាស្ត្រ ដោយការចិញ្ចឹមមានលក្ខណៈខុសៗគ្នា÷

- ការចិញ្ចឹមបែបធម្មជាតិ÷ ដោយផ្តល់ចំណីដូចជាកន្ទក់បន្តិចបន្តួច ត្រូវមានទីតាំងធំទូលាយសម្បូរទៅដោយព្រៃឈើដែលអាចរកអាហារបានដូចជា រុក្ខជាតិតូចៗ ស្មៅ និងសត្វល្អិតមួយចំនួនសម្រាប់ស្វែងរកបានជាប្រចាំថ្ងៃ។
- ការចិញ្ចឹមពាក់កណ្តាលប្រពលវប្បកម្ម÷ ដោយផ្តល់មេចំណី កន្ទក់ ពោត កាកសណ្តែកសៀង សំបកបង្គា ផ្លែចេកទុំ ដើមចេក បន្លែចាស់ៗ កាកសំណល់ផ្ទះបាយ វត្ថុធាតុដើមក្នុងតំបន់ផ្សេងៗ។

## ៣-៣-ការរៀបចំទ្រុង

អាចរៀបចំទ្រុងទទឹង៣ម៉ែត្រ បណ្តោយ៣ម៉ែត្រ កម្ពស់ជញ្ជាំង ១,៥ម៉ែត្រ សម្រាប់មេ ១ក្បាល ដើម្បីជៀសវាងកុំឱ្យជ្រូកលោតចេញ ឬអាចចាក់បេតុងដើម្បីរាំងការគាស់កាយចេញតាមបាតទ្រុង។

-**<u>ដំបូល</u>**÷អាចធ្វើពីស្បូវ ស្លឹកត្នោត ស័ង្កសី ក្បឿង។ល។ ដំបូលដែលប្រក់ស្បូវឬស្លឹកត្នោត គឺមានតម្លៃថោក និងត្រជាក់ល្អ។





## ៣-៤-ការផ្តល់ចំណី និងទឹក

-**ការផ្តល់ចំណី**÷ចំណីចាំបាច់សម្រាប់ជ្រូកព្រៃមានស្លឹករុក្ខជាតិ ស្មៅ ឬសឈើ បន្លែ ផ្លែឈើពីធម្មជាតិច្រើនមុខ ហើយអាចជ្រើសរើសចំណីបន្ថែមដូចជា÷ កន្ទក់ ចុងអង្ករ ពោត សណ្តែក ត្រកួន ចកបាយទា កំប្លោក កន្ទំថេត ផ្ទី ស្លឹកដំឡូងជ្វា ដំឡូងមី ស្លឹកបាស ស្លឹកម្រុំ ដើមនិងស្លឹកត្រាវ។ល។

-**ការផ្តល់ទឹក**÷ ជ្រូកព្រៃត្រូវការទឹកជាចាំបាច់ ប្រសិនជ្រូកផឹកទឹកមិនបានគ្រប់គ្រាន់បណ្តាលឱ្យសីតុណ្ហភាពនៅក្នុងខ្លួនកើនឡើង ស្រ្គេស ធ្វើឱ្យការរំលាយអាហារ និងសារធាតុចិញ្ចឹមក្នុងអាហារមិនបានល្អ។



## ៣-៥-ការថែទាំសុខភាពមេជ្រូក

– ការផ្តល់ទឹក និងចំណីពេលជ្រូកមានគភ៌សំខាន់ណាស់ អាចជួយឱ្យមេជ្រូកផលិតទឹកដោះបានល្អ

– កន្លែងមេជ្រូកបង្កើតកូនត្រូវមានអាកាសធាតុ និងមានខ្យល់ចេញចូលល្អ ហើយមានសភាពស្ងប់ស្ងាត់

– សីតុណ្ហភាពក្តៅស្ទុះស្ទាប់ធ្វើឱ្យមេជ្រូកពិបាកដកដង្ហើម និងពិបាកក្នុងការបញ្ចេញកម្លាំងបង្កើតកូន

## ៣-៦-ការថែទាំសុខភាពកូនជ្រូក

-កូនជ្រូកទើបនឹងកើតត្រូវផ្តល់ភាពកក់ក្តៅដើម្បីថែរក្សាកូនជ្រូកឱ្យមានសុខភាពល្អ ចៀសវាងជំងឺរាគ និងការថែទាំកូនជ្រូកដែលខ្សោយឱ្យរួចផុតពីសេចក្តីស្លាប់

-មេជ្រូកត្រូវមានទឹកដោះគ្រប់គ្រាន់ឱ្យកូនបៅ

-ត្រូវប្រុងប្រយ័ត្នជាពិសេសនៅពេលអាកាសធាតុចុះត្រជាក់ខ្លាំង ដែលធ្វើឱ្យកូនជ្រូកបាត់បង់ថាមពល និងចុះខ្សោយ។

### ៣-៧-ការធ្វើប្រព័ន្ធជីវសុវត្ថិភាព

មិនគួរអនុញ្ញាតឱ្យអ្នកដទៃចូលក្នុងកសិដ្ឋាន ឬទ្រុងជ្រូក និងទិញសាច់ជ្រូកពីខាងក្រៅដែលគ្មានប្រភពច្បាស់លាស់មកបរិភោគ។ ក្នុងករណីចាំបាច់មុនពេលចេញ ចូលកសិដ្ឋាន គឺត្រូវសម្អាតរាងកាយ និងផ្លាស់ប្តូរសម្លៀកបំពាក់ដែលមាននៅក្នុងកសិដ្ឋាន ឬខោអាវដែលបានសម្លាប់មេរោគត្រឹមត្រូវ។

### ៣-៨-តម្លៃ និងទីផ្សារ

**តម្លៃ**÷ ជាធម្មតាកសិករលក់ឱ្យឈ្មួញប្រមូលទិញក្នុងតម្លៃខាងក្រោមនេះ ÷

- ទម្ងន់ចាប់ពី៧គ.ក្រ ទៅ៨គ.ក្រ តម្លៃ៣០០,០០០រៀល/ក្បាល
- ទម្ងន់ចាប់ពី៨គ.ក្រ ទៅ១០គ.ក្រ តម្លៃ ៣៥០,០០០រៀល/ក្បាល
- ទម្ងន់ចាប់ពី១០គ.ក្រ ទៅ១១គ.ក្រ តម្លៃចាប់ពី ៤០០,០០០រៀល/ក្បាល ឡើងទៅ

**ទីផ្សារ**÷ លក់ជ្រូកព្រៃរស់ទៅឱ្យកសិករផ្សេងចិញ្ចឹមបន្ត ឬឈ្មួញកណ្តាលយកទៅលក់បន្ត។

## ៤-គម្រោងអាជីវកម្មចិញ្ចឹមជ្រូកព្រៃសាច់

**៤-១-គម្រោងចិញ្ចឹម**÷ កសិដ្ឋានចិញ្ចឹមជ្រូកព្រៃសាច់ នៅឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ

- ទំហំដី ÷ ៦ ហិកតា
- ទំហំរោងជ្រូក ÷ ទទឹង៧ម៉ែត្រ បណ្តោយ ៣០ម៉ែត្រ
- ចំនួនមេជ្រូក ÷ ៣០ក្បាល តម្លៃ ១,០០០,០០០រៀល/ក្បាល
- ចំនួនជ្រូកបា ÷ ២ក្បាល តម្លៃ ១,០០០,០០០រៀល/ក្បាល
- ប្រភពពូជ ÷ ជ្រើសរើសពីមេបាពូជ ដែលគ្មានប្រវត្តិជំងឺពីខេត្តមណ្ឌលគីរី និងខេត្តកំពង់ស្ពឺ
- រយៈពេលចិញ្ចឹម÷ ១ឆ្នាំ (ផ្តល់កូនបាន ២លើក/ឆ្នាំ)
- ចំណី ÷ ប្រើប្រាស់កន្ទក់ ស្មៅអ៊ីស្រាអែល ខ្ទៅ ខ្យង អនុផលព្រៃឈើ និងបន្លែផ្សេងៗ
- ទិន្នផលកូនជ្រូក÷ ជាមធ្យម ៣០០ក្បាល/ឆ្នាំ
- អត្រារស់ ÷ កូនជ្រូកកើតមករហូតដល់លក់មានអត្រារស់ ៦០% ទៅ ៧០%
- តម្លៃទីផ្សារ ÷ ចន្លោះពី ២៥០,០០០៛ ទៅ ៤៥០,០០០៛/ក្បាល អាស្រ័យលើទម្ងន់
- តម្រូវការទុន ÷ សម្រាប់ចាប់ផ្តើមអាជីវកម្មដំបូង រួមទាំងការសាងសង់ទ្រុង មេបាពូជ និងសម្ភារៈផ្សេង (មិនរាប់បញ្ចូលថ្លៃដីទីតាំង) ត្រូវចំណាយដើមទុនប្រមាណ **៩០,៦៦៥,០០០រៀល** ក្នុងនោះ÷

| ទុនវិនិយោគសាងសង់រោងមេបាព្វជ និងសម្ភារៈផ្សេងៗ | ទុនសម្រាប់ចិញ្ចឹម-ថែទាំក្នុង១ឆ្នាំ (រៀល) | ទឹកប្រាក់សរុប (រៀល) |
|---|---|---|
| 46,675,000 | 43,990,000 | 90,665,000 |

**៤-២-ការវិភាគសេដ្ឋកិច្ច÷** លើការចិញ្ចឹមជ្រូកព្រៃសាច់ក្នុងរយៈពេល១ឆ្នាំរបស់កសិករនៅភូមិខ្នាចកន្ទួត ឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ

សម្រាប់ការចិញ្ចឹមជ្រូកព្រៃសាច់ (មេជ្រូកព្រៃចំនួន៣០ក្បាល បា២ក្បាល) ដោយគិតលើទិន្នផលរយៈពេល១ឆ្នាំ លទ្ធផលក្រោយកាត់រំលស់លើចំណាយថេរ និងចំណាយលើការចិញ្ចឹម÷

| លរ | បរិយាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ១ឯកត្តា | ទឹកប្រាក់សរុប (៛) | ចំនួនរំលស់ | ទឹកប្រាក់សរុប (៛) |
|---|---|---|---|---|---|---|---|
| **១-ចំណូលសរុប/ឆ្នាំ** | | | | | | | **105,000,000** |
| ១ | ចំណូលលក់ជ្រូកព្រៃ(រស់) | ក្បាល | 300 | 350,000 | 105,000,000 | | 105,000,000 |
| **២-ចំណាយសរុប** = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ | | | | | | | **53,907,500** |
| | **ក. ចំណាយប្រែប្រួល** | | | | | | **43,990,000** |
| ១ | ចំណី (កន្ទក់) | គ.ក្រ | 21,900 | 600 | 13,140,000 | | 13,140,000 |
| ៣ | ស្មៅផ្អែមអ៊ីស្រាអែល | គ.ក្រ | 18,250 | 200 | 3,650,000 | | 3,650,000 |
| ៧ | កម្លាំងពលកម្ម | ខែ | 12 | 2,000,000 | 24,000,000 | | 24,000,000 |
| ១០ | ដឹកជញ្ជូនឱ្យអតិថិជន | លើក | 10 | 320,000 | 3,200,000 | | 3,200,000 |
| | **ខ. ចំណាយមិនប្រែប្រួល/ថេរ (ក្នុង១ឆ្នាំ)** | | | | **51,675,000** | | **9,917,500** |
| ១ | រោងជ្រូក (ទទឹង៧ម៉ែត្រ បណ្តោយ៣០ម៉ែត្រ) | រោង | 1 | 12,000,000 | 12,000,000 | 5 | 2,400,000 |
| ២ | សំណាញ់ព័ទ្ធជុំវិញឆ្តាចិញ្ចឹម | គ.ក្រ | 850 | 3,500 | 2,975,000 | 10 | 297,500 |
| ៣ | បង្គោលរបង | ដើម | 200 | 10,000 | 2,000,000 | 10 | 200,000 |
| ៤ | សម្ភារៈស្នូឡាបូមទឹក អំពូល | គ្រឿង | 1 | 2,400,000 | 2,400,000 | 5 | 480,000 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | ស្នូកចំណី | ចំនួន | 10 | 20,000 | 200,000 | 5 | 40,000 |
| ៦ | ស្នូកទឹក | ចំនួន | 10 | 10,000 | 100,000 | 1 | 100,000 |
| ៧ | មេជ្រូក (២៥គ.ក្រ/ក្បាល) | ក្បាល | 30 | 1,000,000 | 30,000,000 | 5 | 6,000,000 |
| ៨ | បាជ្រូក (២៥គ.ក្រ/ក្បាល) | ក្បាល | 2 | 1,000,000 | 2,000,000 | 5 | 400,000 |
| **៣-ចំណេញសរុប** | | | | | | | **51,092,500** |
| **ថ្លៃដើមចំណាយលើការចិញ្ចឹមជ្រូកព្រៃមួយក្បាល** | | | | | | | **179,692** |
| ចំណេញក្នុងការចិញ្ចឹមលក់ជ្រូកព្រៃមួយក្បាល | | | | | | | **170,308** |

***សំគាល់***÷ មេ បាជ្រូកព្រៃដែលចាស់ៗមិនបានយកទៅធ្វើអាជីវកម្មអ្វីទៀតឡើយ (លក់ ឬកាប់សាច់)

## ៤-៣- ការវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់÷

តាមរយៈការសិក្សា ជ្រូកព្រៃអាយុ៦ខែទម្ងន់ចាប់ពី៨គ.ក្រទៅ១០គ.ក្រ តម្លៃទាប២៥០,០០០រៀល/ក្បាល និងតម្លៃខ្ពស់ ៤៥០,០០០រៀល/ក្បាល ឬលើសនេះអាស្រ័យទម្ងន់ជាក់ស្តែង និងរដូវកាលដែលមានតម្រូវការជ្រូកព្រៃខ្ពស់លើទីផ្សារ។

| តម្លៃលក់ | ទិន្នផល | ចំណូល | ចំណាយសរុប | ចំណេញ-ខាត | |
|---|---|---|---|---|---|
| រៀល/ក្បាល | ក្បាល | សរុប(រៀល) | រៀល | រៀល | % |
| 250,000 | 300 | 75,000,000 | 53,907,500 | 21,092,500 | 39% |
| 300,000 | 300 | 90,000,000 | 53,907,500 | 36,092,500 | 67% |
| 350,000 | 300 | 105,000,000 | 53,907,500 | 51,092,500 | 95% |
| 400,000 | 300 | 120,000,000 | 53,907,500 | 66,092,500 | 123% |
| 450,000 | 300 | 135,000,000 | 53,907,500 | 81,092,500 | 150% |

**-ក្នុងករណីទិន្នផលប្រែប្រួល** (ជ្រូកបានតិច ឬច្រើនជាង៣០០ក្បាល/ឆ្នាំ)

| តម្លៃលក់ | ទិន្នផល | ចំណូល | ចំណាយសរុប | ចំណេញ-ខាត | |
|---|---|---|---|---|---|
| រៀល/ក្បាល | ក្បាល | សរុប(រៀល) | រៀល | រៀល | % |
| 350,000 | 200 | 70,000,000 | 53,907,500 | 16,092,500 | 30% |
| 350,000 | 250 | 87,500,000 | 53,907,500 | 33,592,500 | 62% |
| 350,000 | 300 | 105,000,000 | 53,907,500 | 51,092,500 | 95% |
| 350,000 | 350 | 122,500,000 | 53,907,500 | 68,592,500 | 127% |
| 350,000 | 400 | 140,000,000 | 53,907,500 | 86,092,500 | 160% |
| 350,000 | 450 | 157,500,000 | 53,907,500 | 103,592,500 | 192% |

## ៥-ហានិភ័យ វិធានការ និងអនុសាសន៍÷

តាមរយៈនៃការចុះសិក្សានៅកសិដ្ឋានចិញ្ចឹមជ្រូកព្រៃ ឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ឃើញថា ការចិញ្ចឹមជ្រូកព្រៃអាចជួបនូវហានីភ័យមួយចំនួនជាយថាហេតុក្នុងដំណើរការចិញ្ចឹម ដែលនាំឱ្យបង្កផលវិបាក និងផលប៉ះពាល់ដល់សមត្ថភាពផលិតកម្មរបស់ម្ចាស់កសិដ្ឋាន ដូចនេះកសិករគួររៀបចំផែនការឱ្យបានជាក់លាក់ដើម្បីកាត់បន្ថយ ឬគ្រប់គ្រងបានលើហានីភ័យប្រកបដោយប្រសិទ្ធភាពខ្ពស់។

| ល.រ | ប្រភេទហានិភ័យ | ការពិពណ៌នាពីហានិភ័យ | វិធានការ និងអនុសាសន៍ |
|---|---|---|---|
| ១ | ហានិភ័យផលិតកម្ម | មេជ្រូកផ្តល់ទិន្នផលមិនសូវល្អប្រសើរ ដោយសារកូនកាន់តែតិច និងការធំធាត់យឺត (ការជាន់ឈាម) | -ត្រូវប្តូរជ្រូកបាព្រៃចេញរៀងរាល់១ឆ្នាំម្តង<br>-ស្វែងយល់ពីប្រភពបាជ្រូកព្រៃ និងតំបន់កំណើតឱ្យបានច្បាស់លាស់ ដើម្បីជៀសវាងបាជ្រូកមានជាប់ខ្សែពូជជាមួយមេជ្រូក<br>-ជ្រើសរើសមេបាជ្រូកចេញពីហ្វូងមិនធ្លាប់កើតជំងឺ<br>-គួរជ្រើសរើសមេជ្រូកពូជកូនច្រើន<br>-ផ្តល់កន្ទក់ និងបន្លែគ្រប់គ្រាន់សម្រាប់មេបំបៅដោះកូន |
| | | អនុផលព្រៃឈើថយចុះ ដោយសារអាកាសធាតុមានការប្រែប្រួល និង ការកើតឡើងនៃបរិមាណជ្រូក | -រៀបចំដាំរុក្ខជាតិដែលជាចំណីជ្រូកព្រៃបន្ថែមដូចជា ដំឡូងមី ដំឡូងឈើ សណ្តែកដី ទំពាំងឫស្សី ស្មៅ ។ល។<br>-បន្ថែមផ្ទៃដីដោយឡែក សម្រាប់ការដាំចេក និងត្រកួតសម្រាប់កាត់ជាចំណីបន្ថែមឱ្យជ្រូកព្រៃ |
| ២ | ហានិភ័យទីផ្សារ | -តម្លៃប្រែប្រួល ដោយមានការប្រកួតប្រជែងពីជ្រូកព្រៃចិញ្ចឹមបែបប្រពលវប្បកម្ម | -ស្វែងរកដៃគូសហការដែលមានភាពស្មោះត្រង់<br>-ប្រភពផ្គត់ផ្គង់ច្បាស់លាស់<br>-រកទីផ្សារលក់រាយក្នុងតំបន់ទៅអ្នកបរិភោគផ្ទាល់<br>-មានកសិករទទួលទិញទៅធ្វើពូជបន្ត<br>-មានការផ្សព្វផ្សាយឱ្យទូលំទូលាយ<br>-មានភាពស្មោះត្រង់ និងទំនុកចិត្តដល់អតិថិជន |

| | | | |
|---|---|---|---|
| ៣ | **ហានិភ័យ ហិរញ្ញវត្ថុ** | មិនមានប្រាក់បម្រុង សម្រាប់ទប់ទល់ហេតុការណ៍កើតឡើងដោយចៃដន្យ | -មានផែនការអាជីវកម្មច្បាស់លាស់<br>-មានទុនបម្រុងក្រៅពីទុនវិនិយោគ<br>-កំណត់បរិមាណចិញ្ចឹមទៅតាមទំហំទុន<br>-មានផែនការលក់វិលជុំ ដើម្បីទទួលបានប្រាក់ចំណូលទៀងទាត់ |
| ៤ | **ហានិភ័យ បរិស្ថាន** | មានក្លិនស្អុយ និង សម្លេងរំខានប៉ះពាល់ដល់អ្នកជិតខាង | -ជ្រើសរើសទីតាំងដែលឆ្ងាយពីផ្ទះអ្នកជិតខាង<br>-ត្រូវធ្វើអនាម័យសម្អាតទ្រុងជាប្រចាំ និងមានទីស្តុកលាមកជ្រូកឱ្យបានត្រឹមត្រូវ |

## ៦-សេចក្តីសន្និដ្ឋាន

ជ្រូកព្រៃចិញ្ចឹមតាមបែបធម្មជាតិ ជាមុខរបរថ្មីមួយកំពុងពេញនិយមរបស់ប្រជាជននៅតាមតំបន់ជនបទ និងបានចូលរួមចំណែកក្នុងការកាត់បន្ថយការបរបាញ់ជ្រូកព្រៃខុសច្បាប់ផងដែរ។ សម្រាប់មុខរបរចិញ្ចឹមជ្រូកព្រៃទើបតែមានការកើនឡើងអំឡុងពេល៥ឆ្នាំចុងក្រោយនេះ ជាក់ស្តែងប្រទេសជិតខាងមានការចិញ្ចឹមជ្រូកព្រៃយកសាច់ជាយូរមកហើយមុនប្រជាកសិករខ្មែរយើង។ ជ្រូកព្រៃមានភាពធន់ខ្លាំងទៅនឹងអាកាសធាតុប្រែប្រួល ជំងឺ ងាយស្រួលចិញ្ចឹម និងងាយស្រួលផ្តល់ចំណី ព្រមទាំងមានទីផ្សារល្អទាំងការបោះដុំ និងលក់រាយសម្រាប់យកទៅធ្វើពូជបន្ត ជ្រូកសាច់ ឬធ្វើជាជ្រូកខ្វៃ។

តាមការចុះសិក្សាជាក់ស្តែងការចិញ្ចឹមជ្រូកព្រៃរបស់កសិករនៅខេត្តកំពង់ស្ពឺ ដែលបានចិញ្ចឹមមេជ្រូក ៣០ក្បាល បា២ក្បាលសម្រាប់បង្កាត់យកកូនចិញ្ចឹមជាជ្រូកសាច់ គឺអាចទទួលបានជ្រូកសាច់ជាមធ្យម ៣០០ ក្បាល/ឆ្នាំ តម្លៃជាមធ្យម៣៥០,០០០រៀល/ក្បាល ដោយចំណាយថ្លៃដើមផលិតប្រមាណជាង ១៧ ម៉ឺនរៀល/ក្បាល ហើយអាចទទួលបានប្រាក់ចំណេញប្រមាណ ១៧ម៉ឺនរៀល/ក្បាលផងដែរ (ចំណេញស្មើដើម)។

ការចិញ្ចឹមជ្រូកព្រៃកសិករអាចទទួលបានប្រាក់ចំណេញច្រើន ឬតិច អាស្រ័យលើអត្រាបាត់បង់ក្នុងដំណើរការចិញ្ចឹម ទម្ងន់របស់ជ្រូកនៅពេលលក់ និងការដាំព្រៃអាហារសម្រាប់ជ្រូកព្រៃច្រើនប្រភេទ។

ដើម្បីទទួលបានប្រាក់ចំណេញច្រើន កសិករគួរគិតគូរលើកត្តាចាំបាច់មួយចំនួនដូចជា÷ ការជ្រើសរើសពូជជ្រូក ការថែទាំ ការគ្រប់គ្រងហ្វូងជ្រូក និងមានទីផ្សារផ្គត់ផ្គង់ច្បាស់លាស់។

### ប្រភពនៃការសិក្សាស្រាវជ្រាវ÷

កសិករចិញ្ចឹមជ្រូកព្រៃនៅឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ